# Bon Secours Health System, Inc.

# អត្ថបទសង្ខេបស្ដីពីជំនួយហិរញ្ញវត្ថុ

បេសកកម្មរបស់ Bon Secours Health System Inc. (BSHSI) គឺ ធ្វើការផ្តល់សេវាកម្មសុខភាពប្រកបដោយ compassionate និងគុណភាព ទៅដល់អ្នកដែលត្រូវការ ដោយពុំគិតអំពីលទ្ធភាពក្នុងការទូទាត់ចំណាយគ្រឡប់របស់គេឡើយ។ BSHSI ផ្តល់ជំនួយហិរញ្ញវត្ថុ ទៅកាន់អ្នកជម្ងឺទាំងមានធានារ៉ាប់រង និងគ្មានធានារ៉ាប់រង ដែលទទួលបានការសង្គ្រោះបន្ទាន់ ឬការព្យាបាលដែលចាំបាច់នានា ពីសំណាក់ឧបករណ៍បរិក្ខាមន្ទីរពេទ្យរបស់យើងទាំងអស់។

**តើអ្នកណាដែលមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុ?**

គោលការណ៍ជំនួយហិរញ្ញវត្ថុរបស់ BSHSI ("FAP") ផ្តល់នូវជំនួយហិរញ្ញវត្ថុ 100 ភាគរយ សម្រាប់ការសង្គ្រោះបន្ទាន់ ឬការព្យាបាលដែលចាំបាច់នានា ទៅដល់អ្នកជម្ងឺដែលមានធានារ៉ាប់រង និងគ្មានធានារ៉ាប់រងដែលគ្រប់លក្ខខណ្ឌទទួលជំនួយ ជាមួយនឹងចំណូលគ្រួសារដុលប្រចាំឆ្នាំ ត្រឹម ឬទាបជាង 200 ភាគរយនៃបញ្ញត្តិស្ដីពីភាពក្រីក្ររបស់រដ្ឋាភិបាល បច្ចុប្បន្ន (FGP)។ BSHSI ក៏ផ្តល់ផងដែរនូវអត្រាបញ្ចុះថ្លៃទៅកាន់អ្នកជម្ងឺ ដែលចំណូលដុលរបស់គ្រួសារស្ថិតនៅចន្លោះ 201 ភាគរយ ដល់ 400 ភាគរយ របស់ FPG។ បុគ្គលដែលគ្រប់លក្ខខណ្ឌរបស់ FAP ឬបុគ្គលដែលគ្មានការធានារ៉ាប់រងដែលពុំគ្រប់លក្ខខណ្ឌទទួលបានជំនួយហិរញ្ញវត្ថុ នឹងមិនត្រូវគិតថ្លៃលើសពីទំហំទឹកប្រាក់ចេញវិក្កយបត្រជាទូទៅ (AGB) សម្រាប់ការសង្គ្រោះបន្ទាន់ និងការព្យាបាលដែលចាំបាច់នានាដែលបានផ្តល់ជូនអ្នកជម្ងឺដែលទទួលបានការធានារ៉ាប់រងទៅលើការព្យាបាលទាំងនោះទេ។

**តើត្រូវដាក់ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុយ៉ាងដូចម្ដេច?**

បុគ្គលម្នាក់ៗដែលមានក្ដីបារម្ភពីលទ្ធភាពក្នុងការបង់ចំណាយទៅលើការសង្គ្រោះបន្ទាន់ និងការព្យាបាលដែលចាំបាច់នានា អាចដាក់ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុបាន។ ដើម្បីដាក់ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ អ្នកជម្ងឺ (ឬគ្រួសាររបស់ពួកគេ ឬអ្នកផ្តល់ជំនួយដទៃទៀត) ត្រូវបំពេញពាក្យស្នើសុំជំនួយហិរញ្ញវត្ថុរបស់យើង។ ឯកសារថតចម្លងពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ និង FAP អាចទទួលយកបានដោយឥតគិតថ្លៃ ដោយទូរសព្ទទៅកាន់នាយកដ្ឋានបម្រើអតិថិជនរបស់យើង តាមរយៈលេខ (ក្នុងស្រុក) 804-342-1500 ឬ (សេវាឥតគិតថ្លៃ) 877-342-1500។ ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ និង FAP ក៏អាចទទួលយកបានដែរដោយឥតគិតថ្លៃតាមរយៈអ៊ីម៉ែល ដោយផ្ញើសំណើទៅកាន់ប្រអប់ P.O លេខ 742431 Atlanta GA, 30374-2431 របស់កម្មវិធីជំនួយហិរញ្ញវត្ថុរបស់ Bon Secours RGH។ ជាចុងក្រោយ ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ និង FAP អាចយកបានដោយឥតគិតថ្លៃ ដោយទាញយកឯកសារថតចម្លងពីគេហទំព័រ www.fa.bonsecours.com។

**តើខ្ញុំអាចទទួលបានជំនួយក្នុងការបំពេញពាក្យស្នើសុំជំនួយហិរញ្ញវត្ថុនៅទីណា?**

បុគ្គលដែលត្រូវការជំនួយក្នុងការបំពេញពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ អាចទូរសព្ទមកកាន់នាយកដ្ឋានបម្រើអតិថិជនរបស់យើង តាមរយៈលេខទូរសព្ទដែលបានរៀបរាប់ខាងលើ។

**តើមានសេវាកម្មអ្វីខ្លះ?**

រាល់សេវាកម្មសង្គ្រោះបន្ទាន់ចាំបាច់ទាំងអស់ ត្រូវបានគ្របដណ្ដប់ក្រោម FAP រួមបញ្ចូលទាំងសេវាកម្មព្យាបាលដោយពុំសម្រាកនៅមន្ទីរពេទ្យ សេវាកម្មព្យាបាលដោយសម្រាកនៅមន្ទីរពេទ្យ និងសេវាកម្មបន្ទប់សង្គ្រោះបន្ទាន់។ សេវាគ្មានសិទ្ធិ ដូចជា ការវះកាត់ចាំបាច់តែមិនបន្ទាន់ ការកែសម្ផស្ស

និងនីតិវិធីស្តីពីអត្រាការប្រាក់ថេរ អ្នកជម្ងឺដែលជ្រើសរើសមិនប្រើប្រាស់សេវាធានារ៉ាប់រង ឧបករណ៍ព្យាបាលដែលធន់ សេវាព្យាបាលតាមផ្ទះ សេវាកម្មដែលបានផ្តល់ ដោយសារតែគ្រោះថ្នាក់ជាចៃដន្យ និងថ្នាំពេទ្យដែលទទួលបានវេជ្ជបញ្ជា ដែលពុំមានគ្របដណ្តប់ដោយកម្មវិធីជំនួយហិរញ្ញវត្ថុ។ កម្រៃសេវាដែលគិតដោយវេជ្ជបណ្ឌិត និងអ្នកឯកទេសដែលពុំមែនជាបុគ្គលិករបស់ BSHSI និងបុគ្គលដែលផ្តល់សេវានៅក្នុងមន្ទីរពេទ្យ នឹងមិនសាទរជាមួយនឹងកម្មវិធីជំនួយហិរញ្ញវត្ថុឡើយ។ អ្នកត្រូវពិភាក្សាជាមួយនឹងវេជ្ជបណ្ឌិតរបស់អ្នក ឬចូលទៅកាន់គេហទំព័រ www.fa.bonsecours.com ដើម្បីកំណត់ថាតើវេជ្ជបណ្ឌិតបានសហការជាមួយនឹងកម្មវិធីជំនួយហិរញ្ញវត្ថុរបស់ BSHSI ឬទេ។

**តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើខ្ញុំមានចម្ងល់ ឬត្រូវការជំនួយក្នុងការបំពេញពាក្យស្នើសុំនេះ?**

ប្រសិនបើអ្នកត្រូវការជំនួយ អ្នកអាចទំនាក់ទំនងទៅកាន់អ្នកប្រឹក្សាហិរញ្ញវត្ថុ ឬបេឡាករនៅតាមមន្ទីរពេទ្យរបស់យើង ឬទំនាក់ទំនងតាមទូរសព្ទទៅកាន់នាយកដ្ឋានបម្រើអតិថិជនរបស់យើង តាមរយៈលេខ (ក្នុងស្រុក) 804-342-1500 ឬ (សេវាឥតគិតថ្លៃ) 877-342-1500។ ជំនួយអាចទទួលបានផងដែរ តាមរយៈការជួបជាមួយផ្នែកចុះឈ្មោះរបស់មន្ទីរពេទ្យយើង ក៏ដូចជាជួបជាមួយនឹងអ្នកប្រឹក្សាហិរញ្ញវត្ថុ និងបេឡាករនៅតាមមន្ទីរពេទ្យរបស់យើង។ សម្រាប់អ្នកជម្ងឺដែលមិនអាចប្រើប្រាស់ភាសាអង់គ្លេសបាន ការបកប្រែឯកសារនេះ FAP និងពាក្យស្នើសុំជំនួយហិរញ្ញញវត្ថុអាចស្វែងរកបានជាភាសាដទៃទៀត រួមមានភាសាអង់គ្លេស និងភាសាអេស្ប៉ាញ។ សូមទំនាក់ទំនងតាមលេខទូរសព្ទដែលមានខាងលើ ឬចូលទៅកាន់គេហទំព័រ www.fa.bonsecours.com ដើម្បីទាញយកឯកសារបកប្រែនៃអត្ថបទសង្ខេបស្តីពីជំនួយហិរញ្ញវត្ថុ BSHSI FAP និងពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ។